# កំណត់ហេតុកិច្ចប្រជុំលើកទី ១៥
# នៃគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ (គ.ជ.គ.ប.អ.)

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ២០១៤

នាថ្ងៃទីម្ភៃ ខែវិច្ឆិកា ឆ្នាំពីរពាន់ដប់បួន វេលាម៉ោងប្រាំបី និងសាមសិបនាទីព្រឹក នៅសណ្ឋាគារកាំបូឌីណាយ៉ា រាជធានីភ្នំពេញ មានរៀបចំប្រជុំលើកទី១៥ នៃគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ (គ.ជ.គ.ប.អ.) ក្រោមអធិបតីភាព ឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធាន គ.ជ.គ.ប.អ. និងដោយមានការចូលរួមពីឯកឧត្តម លោកជំទាវ ជាអនុប្រធាន និងសមាជិក សមាជិកា នៃគ.ជ.គ.ប.អ. ចំនួន ២០ក្រសួង ស្ថាប័ន និងក្រុមបច្ចេកទេសការងារប្រែប្រួលអាកាសធាតុ មន្ត្រីនៃនាយកដ្ឋានប្រែប្រួលអាកាសធាតុនៃក្រសួងបរិស្ថាន និងលេខាធិការដ្ឋាន គ.ជ.គ.ប.អ. សរុបចំនួន ៥២ រូប។

ជាកិច្ចចាប់ផ្តើម ឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធាន គ.ជ.គ.ប.អ. បានស្វាគមន៍ដល់ឯកឧត្តម លោកជំទាវជាអនុប្រធាន សមាជិក សមាជិកា នៃគ.ជ.គ.ប.អ. និងសមាជិកដែលបានចូលរួមក្នុងអង្គប្រជុំ។ ឯកឧត្តមបានលើកឡើងពីគោលបំណងនៃកិច្ចប្រជុំលើកទី១៥ នេះគឺ ដើម្បីពិនិត្យវឌ្ឍនភាពនៃការអនុវត្តសកម្មភាពចម្បងៗទាក់ទងនឹងការប្រែប្រួលអាកាសធាតុ និងពិភាក្សាប្រធានបទសំខាន់ៗនៃកិច្ចចរចាស្តីពីការប្រែប្រួលអាកាសធាតុ និងជំហរកម្ពុជាសម្រាប់សន្និសីទកំពូលបណ្តាភាគីលើកទី ២០ នៃអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (CoP 20)។ ឯកឧត្តមប្រធានអង្គប្រជុំ បានបញ្ជាក់ថា ក្រសួងបរិស្ថានកំពុងធ្វើកំណែទម្រង់រចនាសម្ព័ន្ធ ការងារអភិវឌ្ឍន៍បៃតង ប្រែប្រួលអាកាសធាតុ និងជីវៈចម្រុះ នឹងត្រូវដាក់ឱ្យស្ថិតនៅក្រោមក្រុមប្រឹក្សាអភិវឌ្ឍន៍ដោយចីរភាពតែមួយ ដើម្បីងាយស្រួលធ្វើការងារ និងធានាប្រសិទ្ធិភាពខ្ពស់។

## លទ្ធផលសំខាន់ៗនៃកិច្ចប្រជុំ មានបង្ហាញជូនដូចខាងក្រោម៖

### របៀបវារៈទី១៖ របាយការណ៍សង្ខេបពីលទ្ធផលសម្រេចបានរបស់ គ.ជ.គ.ប.អ.

ឯកឧត្តម ទិន ពន្លក អគ្គលេខាធិការនៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង នៃក្រសួងបរិស្ថាន បានរាយការណ៍ពីប្រវត្តិ និងសមិទ្ធិផលសំខាន់ៗ ដែលបានសម្រេចចាប់តាំងពីការបង្កើត គ.ជ.គ.ប.អ. នាថ្ងៃទី ២៤ ខែមេសា ឆ្នាំ២០០៦ រហូតមកដល់បច្ចុប្បន្ន រួមមាន ១)ការសម្របសម្រួលបង្កើតក្រុមបច្ចេកទេសការងារប្រែប្រួលអាកាសធាតុ ២)ការសម្របសម្រួលរៀបចំវេទិកាជាតិស្តីពីការប្រែប្រួលអាកាសធាតុចំនួន ៣លើក ៣)ការអនុម័តគម្រោងយន្តការអភិវឌ្ឍន៍ស្អាត (CDM) ចំនួន ១០ ៤)សម្របសម្រួលការរៀបចំចងក្រង និងអនុវត្តផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ២០១៤-២០២៣ ៥)សម្របសម្រួល និងផ្តល់ការគាំទ្រដល់ក្រសួង-ស្ថាប័នចំនួន ៨ ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យចំនួន ១៣ និងមានក្រសួងចំនួន៦ផ្សេងទៀត កំពុងរៀបចំបញ្ចប់ផែនការសកម្មភាពលើវិស័យរបស់ខ្លួន។ (ឯកសារលម្អិតមានជូនភ្ជាប់នូវឧបសម្ព័ន្ធទី១)។

### របៀបវារៈទី២៖ កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា (CCCA) ដំណាក់កាល ទី១ និងសេចក្តីសង្ខេប CCCA ដំណាក់កាលទី ២

លោក ម៉ា ច័ន្ទសុទ្ធា អនុប្រធាននាយកដ្ឋានប្រែប្រួលអាកាសធាតុ បានបង្ហាញពីលទ្ធផលរបស់គម្រោងកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុដំណាក់កាលទី១ដែលបានទទួលការគាំទ្រពីដៃគូអភិវឌ្ឍន៍ដូចជាDanida, EU, Sida និង UNDP នូវទឹកប្រាក់ចំនួន ១០,៨ លានដុល្លាអាមេរិក ដោយសម្រេចបាននូវ ១)ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុរយៈពេល១០ឆ្នាំ ២)ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពតាមវិស័យរបស់ក្រសួង ស្ថាប័នចំនួន៨

ហើយក្រសួងចំនួន៦ផ្សេងទៀតកំពុងស្ថិតក្នុងការរៀបចំ ៣)ក្របខណ្ឌជាតិពិនិត្យតាមដាន និងវាយតម្លៃការប្រែប្រួលអាកាសធាតុ ៤)សេចក្តីព្រាងក្របខណ្ឌច្បាប់ពាក់ព័ន្ធ ៥)សេចក្តីព្រាងក្របខណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាធាតុ ៦)គម្រោងសាកល្បងបន្សាំនឹងការប្រែប្រួលអាកាសធាតុនៅថ្នាក់មូលដ្ឋានចំនួន២០គម្រោង និងសមិទ្ធិផលផ្សេងៗជាច្រើនទៀត។

បន្ទាប់មក លោក ម៉ា ច័ន្ទសុទ្ធា ក៏បានបង្ហាញពីកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុដំណាក់កាលទី២ ដែលមានរយៈពេល ៥ឆ្នាំ ចាប់ពីខែកក្កដា ឆ្នាំ២០១៤ ដល់ ខែមិថុនា ឆ្នាំ២០១៩ ដែលមានទឹកប្រាក់ចំនួន១២,៣ លានដុល្លាអាមេរិកពីសហភាពអឺរ៉ុប ប្រទេសស៊ុយអែដ និងកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ ដែលកម្មវិធីនេះផ្តោតលើលទ្ធផលចំនួន៣ធំៗ។ (ឯកសារលម្អិតមានជូនភ្ជាប់នូវឧបសម្ព័ន្ធទី២)។

របៀបវារៈទី៣៖ វឌ្ឍនភាពនៃការអនុវត្តកម្មវិធីសាកល្បងសម្រាប់ភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ (PPCR)

លោក អ៊ូ ច័ន្ទធារិទ្ធិ អនុប្រធាននាយកដ្ឋានប្រែប្រួលអាកាសធាតុ បានបង្ហាញអំពីប្រវត្តិនៃកម្មវិធីសាកល្បងសម្រាប់ភាពធន់នឹងការប្រែប្រួលអាកាសធាតុ(PPCR) ថា កម្មវិធីនេះមានទឹកប្រាក់សរុប ៩១ លានដុល្លាអាមេរិក ដែលទឹកប្រាក់ ៥០ លានដុល្លាអាមេរិកជាហិរញ្ញប្បទានឥតសំណង និង ៣៦ លានដុល្លាសហរដ្ឋអាមេរិកជាហិរញ្ញប្បទានសម្បទាន និង ចំនួន ៥ លានដុល្លាអាមេរិកទៀតកំពុងស្នើសុំពីអនុគណៈកម្មាធិការកម្មវិធីសាកល្បងសម្រាប់ភាពធន់នឹងអាកាសធាតុ(PPCR) ក្រោមមូលនិធិវិនិយោគអាកាសធាតុ (CIF) តាមរយៈធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដែលអនុវត្តលើគម្រោងបច្ចេកទេសចំនួន ១ និងគម្រោងវិនិយោគចំនួន ៧ ដែលកំពុងអនុវត្តដោយក្រសួងពាក់ព័ន្ធ។ (ឯកសារលម្អិតមានជូនភ្ជាប់ឧបសម្ព័ន្ធទី៣)។

អង្គប្រជុំបានសំណូមពរ ដូចខាងក្រោម៖

- ស្នើសុំដល់ក្រសួង-ស្ថាប័នបន្តកិច្ចសហការលើការអនុវត្តគម្រោងបញ្ជ្រាបភាពធន់នឹងអាកាសធាតុឱ្យមានប្រសិទ្ធភាពខ្ពស់
- សូមមេត្តាជម្រុញការអនុវត្តគម្រោងវិនិយោគនៃកម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ(SPCR) ឱ្យកាន់តែមានប្រសិទ្ធភាពដោយមានការតាមដាន និងត្រួតពិនិត្យ ស្របតាមសូចនាកររបស់គម្រោងកំណត់ ដោយស្របនឹងក្របខណ្ឌយុទ្ធសាស្ត្របន្សាំប្រែប្រួលអាកាសធាតុកម្រិតគម្រោង កម្មវិធី តាមវិស័យ និងថ្នាក់ជាតិ តំបន់ដូចជាមហាអនុតំបន់មេគង្គ ការអនុវត្តការអភិរក្សជីវចម្រុះច្រករបៀង និងការសង់ផ្លូវថ្នល់ទីក្រុង។ អង្គប្រជុំបានសុំឱ្យមានការកែតម្រូវតួលេខ ទឹកប្រាក់របស់គម្រោងសរុបមានចំនួន ៨៥ លានដុល្លាអាមេរិកជាឥណទាន និង ៦លានជាជំនួយបច្ចេកទេសស្មើនឹង ៩១ លានដុល្លាអាមេរិកដែលទឹកប្រាក់ទាំងនេះនឹងវិនិយោគទៅលើវិស័យ៣សំខាន់ គឺ ធនធានទឹក ហេដ្ឋារចនាសម្ព័ន្ធ និងកសិកម្ម និងមានទឹកប្រាក់ចំនួន១០ លានដុល្លាសម្រាប់ជំនួយបច្ចេកទេស និងគម្រោងវិនិយោគចំនួន៧ ដែលក្នុងនោះមានគម្រោងមានស្រាប់ចំនួន ៣ និងគម្រោងថ្មីចំនួន ៤ ត្រូវបានអនុវត្ត។ គម្រោងមិនត្រូវពឹងផ្អែក លើក្រុមទីប្រឹក្សាទាំងស្រុងនោះទេ យើងត្រូវតែបញ្ជូនមន្ត្រីរដ្ឋាភិបាលក្នុងការទទួលខុសត្រូវ និងបង្កើនសមត្ថភាព និងមានភាពជាម្ចាស់លើគម្រោងទៅតាមសកម្មភាពអទិភាពរបស់ក្រសួង និងប្រើប្រាស់ហិរញ្ញប្បទានឱ្យមានប្រសិទ្ធិភាពខ្ពស់ និងមាននិរន្តរភាព ។
- ឯកឧត្តមរដ្ឋមន្ត្រី បានណែនាំឱ្យសមាជិក សមាជិកា តំណាងក្រសួង ត្រូវរៀបចំផែនការយុទ្ធសាស្ត្រសម្រាប់ដាក់ជូនម្ចាស់ជំនួយ ដើម្បីចូលរួមជួយគាំទ្រផែនការសកម្មភាពរបស់ក្រសួងមិនត្រូវឱ្យម្ចាស់ជំនួយជាអ្នកចង្អុលបង្ហាញឱ្យយើងជាអ្នកអនុវត្តនោះទេ។

របៀបវារៈទី៤ ៖ បច្ចុប្បន្នភាពគម្រោងប្រែប្រួលអាកាសធាតុផ្សេងៗកំពុងរៀបចំ និងអនុវត្ត

លោក ស៊ុំ ធី ប្រធាននាយកដ្ឋានប្រែប្រួលអាកាសធាតុ នៃក្រសួងបរិស្ថាន បានបង្ហាញជូនដល់អង្គប្រជុំពីបច្ចុប្បន្នភាពនៃដំណើរការអនុវត្តផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ក៏ដូចជាផែនការផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពប្រែប្រួលអាកាសធាតុតាមវិស័យ។ គម្រោង/កម្មវិធីសរុបចំនួន ២៨ បាននិងកំពុងអនុវត្ត និងខ្លះទៀតនឹងត្រូវអនុវត្តពីឆ្នាំ ២០០៩ ដល់ ២០២២ ក្នុងនោះ គម្រោង/កម្មវិធីចំនួន៣ កំពុងស្ថិតក្រោមការរៀបចំជាសំណើពេញលេញ ហើយមានក្រសួង/ស្ថាប័នដែលកំពុងអនុវត្តគម្រោងមានដូចជា៖ ក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងកិច្ចការនារី គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ គណៈកម្មាធិការជាតិទន្លេមេគង្គ ដែលទទួលជំនួយពីដៃគូអភិវឌ្ឍន៍ និងម្ចាស់ជំនួយរួមមាន៖ UNDP, ADB, EU, UNEP, FAO, USAID, AusAID, Sida, JICA, ធនាគារនាំចេញ-នាំចូលកូរ៉េ, មូលនិធិអភិវឌ្ឍន៍នរ៉ឌិក និង GEF លើថវិកាប៉ាន់ស្មានសរុបប្រមាណ ២៤៨ លានដុល្លារអាមេរិក ក្នុងនោះប្រមាណ ២១២ លានដុល្លារអាមេរិកជាជំនួយឥតសំណង (ឯកសារលម្អិតមានជូនភ្ជាប់ឧបសម្ព័ន្ធទី៤)។

របៀបវារៈទី៥ ៖ ការសិក្សាច្បាប់ពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ នៅកម្ពុជា

ឯកឧត្តម ទិន ពន្លក អគ្គលេខាធិការក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង បានធ្វើបទឧទ្ទេសនាមជូនដល់ គ.ជ.គ.ប.អ. ពីលទ្ធផលបឋមនៃការសិក្សាច្បាប់ពាក់ព័ន្ធការប្រែប្រួលអាកាសធាតុ ដែលបានផ្តោតលើចំណុចសំខាន់៣ គឺ៖ ១)ក្របខណ្ឌច្បាប់ប្រែប្រួលអាកាសធាតុ ដែលជាច្បាប់ពេញលេញរបស់រដ្ឋាភិបាល ហើយកន្លងមកត្រូវបានប្រើប្រាស់ដោយប្រទេសជឿនលឿន និងប្រទេសកំពុងអភិវឌ្ឍន៍ (ហ្វីលីពីន ម៉ិចស៊ិកកូ) ២)ច្បាប់ប្រែប្រួលអាកាសធាតុមានដែនកំណត់ ដែលជាច្បាប់ ឬបទប្បញ្ញត្តិនីមួយៗផ្តោតលើបញ្ហាជាក់លាក់នៃការប្រែប្រួលអាកាសធាតុ (ដូចជាក្នុងប្រទេសវៀតណាម ឥណ្ឌូនេស៊ី) ៣)ច្បាប់តាមវិស័យដែលមានការចែងអំពីការប្រែប្រួលអាកាសធាតុ ដែលការប្រែប្រួលអាកាសធាតុ ត្រូវបានបញ្ចូលទៅក្នុងច្បាប់ ឬបទប្បញ្ញត្តិតាមវិស័យ (តាមវិធីបញ្ច្រាប)។

ឯកឧត្តមក៏បានបង្ហាញផងដែរពីភាពខ្វះចន្លោះនៃច្បាប់ពាក់ព័ន្ធការប្រែប្រួលអាកាសធាតុនៅកម្ពុជា ដែលទាក់ទងនឹងរចនាសម្ព័ន្ធស្ថាប័នបច្ចុប្បន្ន និងភាពមិនមានច្បាប់ជាក់លាក់អំពីការប្រែប្រួលអាកាសធាតុ ហើយវិស័យខ្លះនៅពុំទាន់បានបង្កើតច្បាប់ក្របខណ្ឌទូទៅរបស់ខ្លួននៅឡើយទេ។ ការសិក្សាក៏បានផ្តល់ជម្រើសចំនួន២ សម្រាប់ថ្នាក់ដឹកនាំធ្វើការពិចារណារួមមាន៖

ជម្រើសទី១៖ ការរៀបចំក្របខណ្ឌច្បាប់ប្រែប្រួលអាកាសធាតុ

- រៀបចំច្បាប់ពេញលេញមួយ ដែលពាក់ព័ន្ធជាមួយស្ថាប័នរដ្ឋាភិបាលនៅគ្រប់លំដាប់ថ្នាក់
- គូសបញ្ជាក់ និងពង្រឹងការទទួលខុសត្រូវរបស់ស្ថាប័នទាំងអស់
- រួមបញ្ចូល និងគូសបញ្ជាក់នូវខ្លឹមសារនៃ CCCSP ព្រមទាំងយុទ្ធសាស្ត្រ និងផែនការសកម្មភាពតាមវិស័យនានា
- បង្កើតឱ្យមានការគាំទ្រហិរញ្ញវត្ថុ

ជម្រើសទី២៖ ពង្រឹងបន្ថែមច្បាប់ដែលមានស្រាប់សម្រាប់ស្ថាប័ន

- ការកែសម្រួល និងធ្វើបច្ចុប្បន្នភាពលើរចនាសម្ព័ន្ធស្ថាប័ន៖ព្រះរាជក្រឹត្យស្តីពី គ.ជ.គ.ប.អ. និងអនុក្រឹត្យស្តីពីលេខាធិការដ្ឋាន គ.ជ.គ.ប.អ. និង ក្រុមបច្ចេកទេសការងារប្រែប្រួលអាកាសធាតុ
- ទោះជាយ៉ាងណាក៏ដោយ គេនៅតែអាចត្រូវការឱ្យមានច្បាប់/អនុក្រឹត្យបន្ថែមទៀតទៅអនាគត៖
    - ដើម្បីធានាថា ក្រសួងពាក់ព័ន្ធមានអាណត្តិច្បាស់លាស់សម្រាប់អនុវត្តផែនការសកម្មភាព

• ដើម្បីគាំទ្រដល់គោលនយោបាយ ឬយុទ្ធសាស្ត្រអាកាសធាតុជាក់លាក់ ដូចជា REDD

ក្រៅពីជម្រើសទាំង២ខាងលើ លទ្ធផលនៃការសិក្សាបានផ្តល់ជម្រើសផ្សេងៗជាច្រើនទៀតទាក់ទងកំណែទម្រង់ច្បាប់ដែលមានស្រាប់ និងទៅអនាគត និងគាំទ្រការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងសេចក្តីព្រាងច្បាប់នានាស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ ការគ្រប់គ្រងធនធានទឹក ។ល។ (ឯកសារលម្អិតមានជូនភ្ជាប់ឧបសម្ព័ន្ធទី៥)។

ឯកឧត្តមរដ្ឋមន្ត្រីប្រធានអង្គប្រជុំ បានបញ្ជាក់ថា៖

• ក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុបានរក្សាទុកថវិកាជាតិសម្រាប់ក្រសួងបរិស្ថាននូវថវិកាចំនួន ៥លានដុល្លារអាមេរិកសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ឆ្នាំក្រោយ ដើម្បីឆ្លើយតបនឹងគោលនយោបាយប្រឡងប្រណាំងសំអាតទីក្រុងស្អាត សំណល់រឹង សំណល់រាវ។
• សម្រាប់ទឹកជំនន់ទឹកភ្លៀងនៅរាជធានីភ្នំពេញ ក្រសួងបរិស្ថានបានកំពុងទាក់ទងក្រុមហ៊ុនឯកជនក្នុងស្រុកមួយចំនួន ដើម្បីធ្វើប្រឡាយ ប្រព័ន្ធរំដោះទឹក និងស្ថានីយ៍បូមទឹកចេញក្រៅក្រុង ដើម្បីបញ្ចៀសជំនន់ទឹកភ្លៀងពីរាជធានីភ្នំពេញ។

ឯកឧត្តម ទី សុគន្ធ បានចូលរួមយោបល់ និងលើកសំណើដូចខាងក្រោម៖

• គាំទ្រចំពោះការបង្កើតក្រុមប្រឹក្សាអភិវឌ្ឍន៍ដោយចីរភាព និងទស្សនៈល្អដែលបានរកឃើញ តែទស្សនៈទាំងអស់នោះហាក់មានការលំបាកក្នុងការអនុវត្ត ឧទាហរណ៍ ដូចជា ការគ្រប់គ្រងទីជម្រាលដោយទទួលបន្ទុកគ្រប់វិស័យទាំងអស់ ហេតុនេះតាមបទពិសោធន៍យើងគួរបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅគ្រប់វិស័យផ្សេងៗ។
• គាំទ្រចំពោះជម្រើសទាំងពីរនៃការបង្កើតច្បាប់ប្រែប្រួលអាកាសធាតុ ដែលអាចឱ្យយើងងាយទាក់ទាញជំនួយការចាប់អារម្មណ៍ និងជម្រើសដែលអាចធ្វើវិសោធនកម្មលើច្បាប់ដែលមានស្រាប់ ដោយយើងអាចអនុវត្តសាកល្បងនូវជម្រើសណាមួយ ហើយនៅពេលមានការរាំងស្ទះយើងអាចដោះស្រាយ និងរៀនសូត្រ ឬក៏យើងអាចដំណើរការទៅទាំង២។
• ពាក់ព័ន្ធនឹងផែនការសកម្មភាពឆ្លើយតបការប្រែប្រួលអាកាសធាតុ ឯកឧត្តមបានស្នើឱ្យដាក់បញ្ចូលផែនការសកម្មភាពទាំងអស់ទៅជារបស់ជាតិតែមួយ និងពិនិត្យមើលចំណុចត្រួតស៊ីគ្នា និងផលិតឱ្យចេញជាឯកសារឯកភាពជាតិមួយសម្រាប់បង្ហាញទៅអន្តរជាតិ និងម្ចាស់ជំនួយ។
• ស្នើកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុជំហានទី២ ពិចារណាលើការបែងចែកធនធានទៅតាមវិស័យអាទិភាពជាក់ស្តែង ហើយវិស័យកសិកម្ម ជាវិស័យដែលមានអទិភាព និងជួយគាំទ្រដល់ជីវភាពសហគមន៍។

ឯកឧត្តមប្រធានអង្គប្រជុំបានបញ្ជាក់ថា៖ ច្បាប់នេះជាការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងច្បាប់ដែលមានស្រាប់នៅតាមវិស័យ យើងមិនមានបំណងបង្កើតច្បាប់ថ្មីស្តីពីការប្រែប្រួលអាកាសធាតុនោះទេ ឧទាហរណ៍ ក្រសួងអភិវឌ្ឍន៍ជនបទបានធ្វើផ្លូវតាមស្តង់ដារ ដែលអាចបន្សាំការប្រែប្រួលអាកាសធាតុ វិស័យឯកជនក៏បានចូលរួមផងដែរ ដូចជាហាងកាហ្វេ Brown ដែលធ្វើអាគារតម្រូវតាមអតិថិជន និងការប្រើប្រាស់ថាមពល ដើម្បីឱ្យអាគារត្រជាក់ និងក្រសួងសេដ្ឋកិច្ចក៏បានដាក់ពន្ធលើសំបុត្រយន្តហោះ២ ទៅ៣ដុល្លារសម្រាប់សម្រាប់វិស័យបរិស្ថានដែរ។

របៀបវារៈទី៦ ៖ ការរៀបចំក្របខណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ

ឯកឧត្តម ទិន ពន្លក អគ្គលេខាធិការក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង បានធ្វើបទបង្ហាញការរៀបចំក្របខណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ ដែលជាសមាសធាតុសំខាន់ ដោយសារក្រសួងស្ថាប័ននានា បានរៀបចំផែនការ

យុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុតាមវិស័យដោយរួមបញ្ចូលការពិនិត្យតាមដាន និងវាយតម្លៃ និងក្របខណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ។ ក្របខណ្ឌនេះ បានបញ្ចូលនូវការប៉ាន់ប្រមាណការខាតបង់ថ្លៃចំណាយ និងផលចំណេញក្នុងករណីគ្មានចំណាត់ការ ដោយរហូតដល់ឆ្នាំ ២០៥០ ការបាត់បង់ប្រចាំឆ្នាំត្រូវបានប៉ាន់ស្មានថាមាន៣,៥%នៃGDP (១,៥%នៃ GDP រហូតដល់ឆ្នាំ ២០៣០)។ (ឯកសារលម្អិតមានជូនភ្ជាប់ឧបសម្ព័ន្ធទី៦)។

របៀបវារៈទី៧៖ លទ្ធផលសន្និសីទកំពូលសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ និងជំហរកម្ពុជាសម្រាប់ CoP20

លោក ជា ចន្ទន៍ធូ អនុប្រធាននាយកដ្ឋានប្រែប្រួលអាកាសធាតុ នៃក្រសួងបរិស្ថាន បានបង្ហាញពីលទ្ធផលនៃសន្និសីទកំពូលលើកទី១៩ នៃអនុសញ្ញាសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ដែលបានប្រារព្ធនៅប្រទេសប៉ូឡូញឆ្នាំមុន និងជម្រាបជូនអំពីប្រធានបទសំខាន់ៗដែលមាននៅក្នុងរបៀបវារៈនៃសន្និសីទកំពូលលើកទី២០ ដែលនឹងប្រព្រឹត្តទៅនៅខែធ្នូ ឆ្នាំ២០១៤ នៅទីក្រុងលីម៉ា ប្រទេសប៉េរូ។ បន្ទាប់មកក៏មានការបង្ហាញអំពីជំហររបស់ប្រទេសកម្ពុជាក្នុងកិច្ចចរចានៃសន្និសីទកំពូលលើកទី២០ ។ (ឯកសារលម្អិតមានជូនភ្ជាប់ឧបសម្ព័ន្ធទី៧)។

ឯកឧត្តមរដ្ឋមន្ត្រី បានបញ្ជាក់ប្រាប់អង្គប្រជុំថា៖

- បច្ចុប្បន្ននាយកដ្ឋានប្រែប្រួលអាកាសធាតុ ស្ថិតក្រោមអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ដោយគ្រោងនឹងដាក់ឱ្យនៅក្រោមអគ្គលេខាធិការដ្ឋានអភិវឌ្ឍន៍ដោយចីរភាព ដើម្បីងាយស្រួលក្នុងការសម្របសម្រួល ដោយសារការប្រែប្រួលអាកាសធាតុជាបញ្ហាអន្តរវិស័យ តម្រូវឱ្យរៀបចំផ្នែកគោលនយោបាយច្រើនជាងការអនុវត្ត ហើយមិនត្រឹមតែសម្របសម្រួលនៅក្នុងក្រសួងប៉ុណ្ណោះទេ ថែមទាំងអន្តរក្រសួងទៀតផង។ ដូចនេះយើងត្រូវបង្កើតយន្តការថ្មីដោយលុបចោលនូវនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ដោយឱ្យនាយកដ្ឋានជំនាញធ្វើការជាមួយដៃគូអភិវឌ្ឍន៍ ដោយមានឯកឧត្តម សៅ សុភាព (នាយកខុទ្ទកាល័យ) ជាអ្នកសម្របសម្រួលគម្រោងទាំងអស់របស់ក្រសួងបរិស្ថាន។
- បញ្ហាប្រែប្រួលអាកាសធាតុជាបញ្ហាប្រឈមរបស់មនុស្សលោកទាំងមូលដែលយើងត្រូវយកចិត្តទុកដាក់ និងចូលរួមដោះស្រាយ ដោយឡែកនៅប្រទេសកម្ពុជាយើង ដូចជានៅស្រុកព្រៃនប់ ខេត្តព្រះសីហនុ ប្រសិនជាក្រុមការងារតំបន់ឆ្នេរមិនយកថវិកាធ្វើទំនប់ទប់ទឹកប្រៃសម្រាប់ផ្ទៃដីប្រមាណ ១០.០០០ ហិកតានោះទេ ជីវភាពប្រជាជននឹងជួបប្រទះនឹងការលំបាក។ ទៅថ្ងៃអនាគត ប្រសិនបើមានគ្រោះរាំងស្ងួតកើតឡើង នោះនឹងមានភ្លើងឆេះព្រៃដែលមិនអាចទប់ស្កាត់បាន ហើយយើងក៏មិនមានលទ្ធភាពទប់ស្កាត់បានដែរ។ ថ្វីត្បិតតែយើងមានប្រព័ន្ធធារាសាស្ត្រមួយចំនួន តែនៅមិនទាន់គ្រប់គ្រាន់នៅឡើយ យើងនៅពឹងផ្អែកលើទឹកភ្លៀង ហើយរបបទឹកភ្លៀងមានការប្រែប្រួលច្រើន។ ប្រព័ន្ធលូទឹកនៅរាជធានីភ្នំពេញនៅមិនទាន់រៀបចំបានគ្រប់គ្រាន់នៅឡើយ ដែលតម្រូវឱ្យរៀបចំប្រព័ន្ធលូរំដោះទឹកបន្ថែមទៀត វាជាបញ្ហាដែលប៉ះពាល់ដល់ជីវភាពរស់នៅរបស់ប្រជាជននៅរាជធានីភ្នំពេញរបស់យើង។

- ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ក្រសួងបរិស្ថាន បានរៀបចំឯកសារទស្សនៈទានទីក្រុងស្អាតដែលអាចរស់នៅបាន (Sustainable City) ដែលនឹងធ្វើឱ្យទីក្រុងទាំងអស់ទទួលបាននូវខ្យល់បរិសុទ្ធ និងទឹកស្អាត ដើម្បីធានានូវសុខមាភាពក្នុងការរស់នៅ ដូចដែលរាជធានីភ្នំពេញជាប់ចំណាត់ថ្នាក់នៅអាស៊ានថាជាទីក្រុងមានទឹកស្អាតធានាគុណភាព ចំណែកក្រុងបាត់ដំបងមានខ្យល់បរិសុទ្ធល្អដែលជាប់ចំណាត់ថ្នាក់ជាទីក្រុងស្អាត។ ដូចជាករណីទីក្រុងភ្នំពេញដែលការរៀបចំទីក្រុងពុំមានគិតគូរ ១)ស្ទះចរាចរណ៍ដោយសារគ្មានផ្លូវថ្មើរជើង ២)ពុំមានម្លប់ដើមឈើគ្រប់គ្រាន់តាមដងផ្លូវ ៣)ការប្រើប្រាស់ថាមពលច្រើនសម្រាប់អាគារត្រជាក់ខ្ពស់

ជាដើម។ ក្រសួងបរិស្ថាននឹងធ្វើការជាមួយក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ ដើម្បីធ្វើកូដសម្រាប់អាគារដែលប្រើប្រាស់ថាមពលតិច និងគិតគូរពីបរិស្ថាន។

ឯកឧត្តម បានស្នើឱ្យសមាជិក សមាជិកា គ.ជ.គ.ប.អ. ទាំងអស់ធ្វើកំណត់បង្ហាញ (Aide Memoire) នូវជំហរច្បាស់លាស់ ភាពបត់បែន និងវឌ្ឍនភាពដែលវិស័យនីមួយៗសម្រេចបានបន្ទាប់ពី COP ២០ សម្រាប់ការចរចាដាច់ដោយឡែកជាមួយអង្គទូតនានា ដូចខាងក្រោម៖

**វិស័យដី និងថាមពល៖** ពិនិត្យ និងសិក្សាថាតើយើងបានប្រើប្រាស់ថាមពលកកើតឡើងវិញ និងការប្រើប្រាស់ជីវម៉ាស ការដុតអង្កាម រុក្ខជាតិ មានប៉ុន្មានភាគរយ ហើយទទួលបានថាមពលប៉ុន្មាន ដើម្បីបង្ហាញពីជំហររបស់យើងក្នុងនាមជាប្រជាជាតិមួយរបស់ប្រទេសមួយ ដោយយើងខិតខំកាត់បន្ថយការប្រើប្រាស់ថាមពលដែលប៉ះពាល់ដល់ការប្រែប្រួលអាកាសធាតុទាំងអស់នោះទេ និងជម្រើសនានានៃការផលិតថាមពលទៅតាមបច្ចេកវិទ្យាដែលមិនប៉ះពាល់ដល់ការប្រែប្រួលអាកាសធាតុ។

**វិស័យទេសចរណ៍៖** ឯកឧត្តមបានបញ្ជាក់ថាវិស័យទេសចរណ៍ ដែលរាប់បញ្ចូលតាំងពីសណ្ឋាគារដែលមានច្រើនណាស់នៅទូទាំងប្រទេសជាពិសេសតំបន់ទេសចរណ៍ និងសំបុត្រយន្តហោះដែលត្រូវដាក់បន្ថែម ២ ទៅ ៣ដុល្លាសម្រាប់ពន្ធលើការបញ្ចេញកាបូនជាដើម ដែលជាការចូលរួមក្នុងសេវាកម្មបរិស្ថាន។

**វិស័យពាណិជ្ជកម្ម៖** ដែលមានការជាប់ពន្ធលើការប្រើប្រាស់ប្រេងឥន្ធនៈក្នុងការដឹកជញ្ជូន ដែលយើងត្រូវធ្វើតាមស្តង់ដា និងត្រូវជាប់ពន្ធអាករ។

**ក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ៖** ពិនិត្យមើលថាតើយើងគួរមានគោលនយោបាយអ្វីខ្លះសម្រាប់អណត្តិក្រោយ ដើម្បីសរុបរបាយការណ៍មួយជាផែនទីបង្ហាញផ្លូវ ឬជាការកំណត់បង្ហាញមួយ សម្រាប់ដាក់ជូនអង្គទូត ឧទាហរណ៍ដូចជាកម្ចីតើបានចូលរួមការពារបរិស្ថាន ឬប៉ះពាល់បរិស្ថាន និងការប្រែប្រួលអាកាសធាតុ ដូចជាទូទឹកកកជជុះជាដើម។

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ៖** បង្ហាញវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយក្នុងវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលចូលរួមកាត់បន្ថយការប្រែប្រួលអាកាសធាតុ ដូចជាការរៀបចំសួនបន្លែគ្រួសារ ការអប់រំកសិករ និងការសិក្សាស្រាវជ្រាវដែលមានភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុ។

**ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់៖** ពិនិត្យ និងសិក្សាលទ្ធភាពនៃការរចនាប្លង់អាគារដែលមានមេត្រីភាពជាមួយបរិស្ថាន ដូចជាប្លង់បង្អួច រក្សាកម្តៅ/ត្រជាក់ខាងក្នុងអាគារ ការពារទឹកជំនន់ និងការរៀបចំក្រុងជាដើម។

**ក្រសួងអប់រំ យុវជន និងកីឡា៖** គួរពិចារណាដាក់ការប្រែប្រួលអាកាសធាតុចូលក្នុងកម្មវិធីសិក្សាចាប់តាំងពីថ្នាក់ទី១ ដល់ថ្នាក់ទី១២។

ឯកឧត្តមរដ្ឋមន្ត្រីបានប្រគល់ការងារនេះជូន **ឯកឧត្តម សៅ សុភាព និងឯកឧត្តម ទិន ពន្លក** ធ្វើការងារនេះបន្តជាមួយក្រសួងពាក់ព័ន្ធខាងលើ និងធ្វើរបាយការណ៍វឌ្ឍនភាពជូនឯកឧត្តមរដ្ឋមន្ត្រីប្រធាន គ.ជ.គ.ប.អ. ។

ឯកឧត្តមរដ្ឋមន្ត្រីក៏បានស្នើសុំឱ្យសមាជិក សមាជិកា ទាំងអស់ចូលរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុដូចជាការណែនាំដល់មន្ត្រីរាជការទាំងអស់ត្រូវចេះសន្សំសំចៃថាមពល និងត្រូវចូលរួមឱ្យកាន់តែសកម្មជាងមុន ហើយឯកឧត្តម លោកជំទាវអាចលើកប្រធានបទនានាជូនប្រធានគណៈកម្មាធិការ ដើម្បីកោះប្រជុំជជែកពិភាក្សា។ <u>អង្គប្រជុំ បានឯកភាពចំពោះកិច្ចប្រជុំលើក្រោយរបស់ គ.ជ.គ.ប.អ. នៅ៣ខែក្រោយ ដោយក្រសួងនីមួយៗត្រូវដាក់កំណត់បង្ហាញ (Aide Memoire) បញ្ជាក់លទ្ធផលសម្រេចបាន និងជំហររបស់វិស័យនីមួយៗសម្រាប់ កិច្ចចរចាក្នុងសន្និសីទកំពូលឆ្នាំ ២០១៥។</u>

ជាកិច្ចបញ្ចប់ ឯកឧត្តមប្រធានអង្គប្រជុំ បានធ្វើថ្លែងអំណរគុណដល់ឯកឧត្តម លោកជំទាវជាអនុប្រធាន សមាជិក សមាជិកាទាំងអស់ដែលបានចំណាយពេលវាលាចូលរួមប្រជុំក្នុងរយៈពេល១ព្រឹកនេះ និងបានកំណត់វេលាសម្រាប់កិច្ចប្រជុំនៅបីខែក្រោយ និងបានការកោតសរសើរចំពោះលេខាធិការដ្ឋាន គ.ជ.គ.ប.អ. ដែលបានប្រឹងប្រែងរៀបចំកិច្ចប្រជុំ និងអនុវត្តការងារប្រកបដោយប្រសិទ្ធភាព និងទទួលបានជោគជ័យ។ អង្គប្រជុំបានបញ្ចប់ទៅដោយជោគជ័យទៅតាមរបៀបវារៈ និងការរំពឹងទុក នៅវេលាម៉ោងដប់ពីរព្រឹកនាថ្ងៃខែឆ្នាំដដែល ដោយទទួលបានលទ្ធផលជាផ្លែផ្កាគួរជាទីមោទនៈ៕

រាជធានីភ្នំពេញ, ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៤

**អ្នកធ្វើកំណត់ហេតុ**

**ស៊ុំ ធី**

**ប្រធាននាយកដ្ឋានប្រែប្រួលអាកាសធាតុ**

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែធ្នូ ឆ្នាំ២០១៤

**បានឃើញ និងឯកភាព**

**ឯកឧត្តមរដ្ឋមន្ត្រីប្រធានអង្គប្រជុំ**

**សាយ សំអាល់**